# ព្រឹត្តិបត្រព័ត៌មាន

## គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាប(ធី.អេស.អេស.ឌី)

*ផ្តល់ថវិកាអនុវត្តដោយ៖ ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម រដ្ឋាភិបាលហ្វាំងឡង់ និង រាជរដ្ឋាភិបាលកម្ពុជា*

គម្រោងទន្លេសាប ធី.អេស.អេស.ឌី៖ ជួយកែលម្អជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ប្រមាណជា ៦៣ម៉ឺនគ្រួសារ ក្នុង១៩៦ឃុំ ២៨ស្រុក ក្នុងខេត្ត បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និង ត្បូងឃ្មុំ តាមរយៈ (១) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រដល់ផលិតភាពកសិកម្ម (២)ការបង្កើនសមត្ថភាពបច្ចេកទេសរបស់កសិករខ្នាតតូច (៣) ការផលិត-ផ្គត់ផ្គង់ពូជដំណាំមានគុណភាព និង (៤) ការផ្តល់ព័ត៌មានដល់កសិករ។

## មាតិកាសម្រាប់ត្រីមាសទី៤ ឆ្នាំ ២០១៥


១. ផ្លូវលំល្អសន្សំប្រាក់កាស និងសម្រួលដល់ការដឹកជញ្ជូនកសិផល
២. ដំណាំផ្សិតចំបើងជួយជីវភាពគ្រួសារកាន់តែប្រសើរឡើង
៣. ទិវាបង្ហាញបច្ចេកទេសចិញ្ចឹមមាន់សាច់
៤. កែលម្អជីវភាពគ្រួសារតាមរយ:ចំណូលបន្ថែមពីការភ្ញាស់កូនមាន់
៥. ដំណាំម្រះនាំប្រាក់ច្រើនចូលផ្ទះ


### ១. ផ្លូវលំល្អសន្សំប្រាក់កាស និងសម្រួលដល់ការដឹកជញ្ជូនកសិផល



ផ្លូវលំជាសរសៃឈាមនៃសេដ្ឋកិច្ច ដែលអាចជួយលើកស្ទួយវិស័យកសិកម្មនៅជនបទ។ កំពុងបររទេះគោ បងប្រុស ម៉ឹង សួរ មានវ័យ ៣៩ឆ្នាំ បាននិយាយថា "មុនធ្វើផ្លូវ មានការលំបាកយ៉ាងខ្លាំងក្នុងការដឹកជញ្ជូនកសិផលនានា ប៉ុន្តែបន្ទាប់ពីមានផ្លូវ១ខ្សែរនេះមក បានជួយយ៉ាងច្រើនដល់ការដឹកជញ្ជូន និងជាពិសេសការធ្វើ ដំណើររបស់អ្នកភូមិខ្ញុំ" ។

ដោយពិនិត្យឃើញពីការលំបាក របស់កសិករក្នុងការធ្វើដំណើរទៅដឹកផលដំណាំ ក៏ដូចជាការធ្វើដំណើរឆ្លងកាត់ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានសម្រេចជួសជុលផ្លូវលំក្រាលគ្រួសក្រហមមួយខ្សែ ដែលមានប្រវែង១២០០ម៉ែត្រ ស្ថិតនៅក្នុងភូមិត្រពាំងស្រងែ ឃុំត្រពាំងគ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

មិនមែនតែបងប្រុស ម៉ឹង សួរ និងអ្នកភូមិរបស់គាត់ប៉ុណ្ណោះទេ អ្នកភូមិរាប់ពាន់នាក់ផ្សេងទៀត ក៏បានទទួលផល ពីផ្លូវនេះដែរ។ លោក ឈិន ឈន ជំទប់ទី១ ឃុំត្រពាំងគ ស្រុកព្រៃឈរ ខេត្តកំពង់ចាម បានឱ្យដឹងថា "ផ្លូវលំនេះ បានជួយសម្រួលដល់ប្រជាជនក្នុងភូមិ ប្រហែលជា ៥០គ្រួសារ ធ្វើដំណើរមកដឹកជញ្ជូនកសិផលនារដូវប្រមូលផល និងការធ្វើដំណើរឆ្លងកាត់របស់ ភូមិផ្សេងទៀតផងដែរ"។

ដើម្បីទប់ស្កាត់ការខូចខាតផ្លូវ យើងត្រូវចូលរួមថែរក្សាទាំងអស់គ្នា។ លោក ឈន ជំទប់ទី១ បានមានប្រសាសន៍ថា ឃុំតែងតែប្រជុំ និងប្រកាសដល់ប្រជាពលរដ្ឋទាំងអស់ ឱ្យបានយល់ដឹងពីសារៈសំខាន់ផ្លូវលំនេះ និងការថែរក្សាឱ្យបានគង់វង្សផងដែរ។ ក្នុងនាមប្រជាជនក្នុងឃុំ លោកបានសំដែងនូវ ការសាទរយ៉ាងជ្រាលជ្រៅដល់គម្រោង ដែលបានជួសជុលផ្លូវដែលជា ផ្នែកមួយជួយលើកកម្ពស់វិស័យកសិកម្ម៕

## ២. ដំណាំផ្សិតចំបើងជួយជីវភាពគ្រួសារកាន់តែប្រសើរឡើង



កំពុងតែប្រមូលទិន្នផលផ្សិតចំបើង នៅក្នុងរោងបណ្តុះផ្សិត លោក ហាស់ មាស មានវ័យ ៣៦ឆ្នាំ បាននិយាយថា "ខ្ញុំកំពុងតែប្រញាប់ប្រញាលបង្ហើយការប្រមូលផលផ្សិតរបស់ខ្ញុំ ដូចនេះ ខ្ញុំអាចចាប់ផ្តើមរៀបចំការបណ្តុះផ្សិតមួយវគ្គទៀត។" ដោយនិយាយផង និង យកក្រម៉ាជូតញើសចេញពីថ្ពាស់របស់គាត់ផង លោកមាសបានបញ្ជាក់ថា "ធម្មតានៅពេលនេះ ខ្ញុំកំពុងតែស៊ីឈ្នួលអាឈើ ឱ្យគេឡើយទេ។ ប៉ុន្តែពេលនេះ ខ្ញុំអាចធ្វើជាម្ចាស់លើអាជីវកម្មផ្ទាល់ខ្លួន។"

គ្រួសារ លោក ហាស់ មាស រស់នៅភូមិសុវណ្ណគមន៍ ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចាប់ផ្តើមអាជីវកម្មបណ្តុះផ្សិតចំបើង តាមបែបចំហុយអស់រយៈពេលមួយឆ្នាំជាងហើយ។ ជាមួយនឹងបទពិសោធន៍ថ្មីនេះ លោក ហាស់ មាស ចំណាយពេល និងទុនតិច ហើយទទួលបានទិន្នផល ខ្ពស់។ លោក មាស បានរៀបរាប់ថា "ការបណ្តុះផ្សិតចំបើង តាមបែបចំហុយរៀងរាល់១១ថ្ងៃ នឹងប្រមូលផលម្តងហើយការប្រមូលផល មានរយៈ ពេល៥ថ្ងៃ ទើបអស់ផ្សិតពីរោងបណ្តុះផ្សិត។ ក្នុងដំណាក់កាលប្រមូលផលគឺ ១ថ្ងៃបានពី ២០ ទៅ ៣០ គីឡូក្រាម ។

ដោយសារតែតំរូវការទីផ្សារ និងផលិតកម្មមានការកើនឡើង លោកហាស់ មាស បានធ្វើរោងបណ្តុះផ្សិតចំបើងបន្ថែម ចំនួន៥រោងទៀត ដែលកាលពីដំបូងឡើយ គាត់មានតែមួយរោងទេ ប៉ុន្តែពេលបច្ចុប្បន្ននេះ រោងបណ្តុះផ្សិតបានកើនដល់ ៦រោង។ ជីវភាពគ្រួសារ លោក មាស មានការរីកចម្រើនជាងមុន ដោយសារបានចំណូលចម្បង ពីការលក់ផ្សិតចំបើង។ លោក មាស បានបង្ហើបឱ្យដឹងថា "ផលិតកម្មផ្សិតក្នុង ៦រោងចំណាយ ១ខែ អស់ប្រាក់ ៣លានរៀល ហើយ ចំណេញបានប្រហែល ១លាន៥០ម៉ឺនរៀល"។

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានគាំទ្រក្រុមកែលម្អជីវភាព ដោយផ្តល់ឱ្យរោងបណ្តុះផ្សិតចំបើងមួយ មេផ្សិត ផ្លាស់ស្ទិច និង ថវិកា២០០ដុល្លារ។ លោក យន សុភ័ក្រ មន្ត្រីគាំទ្រកសិកម្មស្រុក បាននិយាយថា "ក្រៅពីសម្ភារ និងថវិកា គម្រោងក៏បានផ្តល់បច្ចេកទេសដល់កសិករ ដូចជា ការសិក្សាពីវិធីសាស្រ្តបណ្តុះផ្សិតច្នេកទេស ចំហុយ ធ្វើរោង ការរើសមេផ្សិតណាល្អៗជាដើម។"



ផ្សិតចំបើងជា ប្រភេទបន្លែដែលមានតម្រូវការ និងការគាំទ្រច្រើនពីប្រជាជនទូទៅ។ ដោយសង្កេតឃើញការលក់ដាច់នៅលើទីផ្សារ លោក មាស មានបំណងពង្រីកបន្ថែមមុខរបរ ដើម្បីផ្គត់ផ្គង់

តម្រូវការទីផ្សារ។ លោកមាស និយាយថា "តាមចិត្តចង់គឺចង់ធ្វើច្រើនជាងនេះ ខ្ញុំមានផែនការពង្រីក៤រោងទៀត នៅថ្ងៃអនាគត។" លោក បាននិយាយដោយ ទឹកមុខញញឹមថា "ជីវភាពគ្រួសារខ្ញុំធូរធារជាងមុន។ ខ្ញុំអាចផ្គត់ផ្គង់ ជីវភាពគ្រួសារបានកូនចៅមិនខ្វះចាយ។ ខ្ញុំទិញបានម៉ូតូមួយគ្រឿង សម្រាប់ដឹកកូនទៅរៀន និងប្រើប្រាស់ក្នុងគ្រួសារ ព្រមទាំងទិញបានទូរទស្សន៍មួយផងដែរ។" ខ្ញុំរីករាយនឹងអ្វីៗដែលខ្ញុំមានសព្វថ្ងៃណាស់ គម្រោងពិតជាបានជួយគ្រួសារខ្ញុំ និងកសិករក្នុងសហគមន៍ ឱ្យបានប្រសើរឡើងមែន៕

## ៣. ទិវាបង្ហាញបច្ចេកទេសចិញ្ចឹមមាន់សាច់



ធ្វើដំណើរចម្ងាយ១០គីឡូម៉ែត្រពីខេត្តកំពង់ចាមឆ្លងកំពង់ចម្លងភូមិថ្មីមហាខ្វងដល់ ភូមិព្រែកតានង់ ស្រុកកោះសូទិន ប្រជាកសិករកំពុងចូលរួមមើល ទិវាបង្ហាញបច្ចេកទេសចិញ្ចឹមមាន់សាច់។ ទិវាបង្ហាញនេះ មានអ្នកចូលរួមសរុបមានចំនួន ៤៧នាក់ដែលរួមមានស្ត្រី ២៦នាក់ផងដែរ។

អេង ស្រុន អាយុ ៣៨ឆ្នាំ និងប្តី ហ៊ូ សុខ អាយុ៤៣ឆ្នាំ ជាកសិករគំរូដែលជ្រើសរើសដោយគម្រោង ដើម្បីចិញ្ចឹមមាន់សាច់។ អ្នកស្រី អេង ស្រុន ចាប់ផ្តើមទទួលមាន់ពីគម្រោង ចំនួន១០០ក្បាល នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ហើយដល់ថ្ងៃប្រមូលផលនៅថ្ងៃទី៥ ខែវិច្ឆកា ឆ្នាំ២០១៥ គឺចំទិវាបង្ហាញនេះ តែម្តងបានចំនួន ៩៥ក្បាល។

ការចិញ្ចឹមមាន់សាច់នេះ ទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈមួយចំនួនដូចជា ទ្រុង ចំណី កូនមាន់ ១០០ក្បាល សំណាញ់ និងស្នូកទឹក ពីគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប។ លោក សុខ នឿន ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម បានឱ្យដឹងថា "មន្ត្រីគម្រោងបានធ្វើការយ៉ាងជិតដល់ ជាមួយនឹងកសិករនៅគ្រប់ដំណាក់កាលនៃការចិញ្ចឹមមាន់សាច់ ព្រមទាំងបានពិនិត្យ តាមដានរាល់សកម្មភាពចិញ្ចឹមមាន់ រៀងរាល់កន្លះខែម្តង ជាពិសេសនៅពេលដែលមាន់មានបញ្ហាកើតឡើងម្តងៗ។"

ការចិញ្ចឹមមាន់យកសាច់ គឺមានការចាប់អារម្មណ៍ខ្លាំងពីកសិករក្នុងភូមិ ដោយសារជាមុខរបរនៅផ្ទះ និងជាប្រភពចំណូលសម្រាប់ទ្រទ្រង់ដល់គ្រួសារផងដែរ។ ជាក់ស្តែងកាចិញ្ចឹមមាន់សាច់ ១០០ក្បាល គិតជាមធ្យមប្រើពេល ១០០ថ្ងៃ និងក្នុង១០០ក្បាល អាចលក់បានដល់ ១.០០០.០០០រៀល។ ពោលពេញដោយទឹកមុខញញឹមក្នុង ទិវាបង្ហាញបច្ចេកទេសចិញ្ចឹមមាន់សាច់ បងស្រី ស្រុន និយាយថា "ខ្ញុំប៉ាន់ប្រមាណការចំណេញ សរុបប្រហែល៤០% ពីការចិញ្ចឹមមាន់សាច់ក្នុងមួយវគ្គនេះ។"



ក្នុងទឹកមុខសប្បាយរីករាយ អ្នកស្រី អេង ស្រុន និយាយថា "មាន់ខ្ញុំបានលទ្ធផលល្អ ខ្ញុំអាចចាប់ផ្តើមលក់មាន់យកលុយសម្រាប់ទ្រទ្រង់គ្រួសាររបស់ខ្ញុំ។ ខ្ញុំមានផែនការចិញ្ចឹមមាន់បន្ថែមចំនួន១៥០ក្បាលទៀតនៅវគ្គបន្ត។"

## ៤. កែលម្អជីវភាពគ្រួសារតាមរយៈចំណូលបន្ថែមពីការភ្ញាស់កូនមាន់

កសិករក្នុងភូមិ តែងតែជួបផលលំបាកក្នុងការរកទិញកូនមាន់ ដោយសារផ្សារនៅឆ្ងាយ។ គាត់ត្រូវទៅទិញកូនមាន់រហូតដល់ជីហែ និងពង្រ។ បញ្ហាលំបាកនេះហើយបានជំរុញឱ្យអ្នកស្រី មានចំណាប់អារម្មណ៍ទៅលើមុខរបរភ្ញាស់កូនមាន់នេះ។ អ្នកស្រីបានឱ្យដឹងថា "ខ្ញុំមានការចាប់អារម្មណ៍ខ្លាំង ព្រោះពិបាកដើររកទិញកូនមាន់មកចិញ្ចឹម មួយវិញទៀត

ចំពេលដែលគម្រោងជ្រើសរើសអ្នកស្ម័គចិត្តចូលរួមភ្ញាស់កូនមាន់ ក៏សុំគេធ្វើទៅ។"



មុខរបរភ្ញាស់កូនមាន់ នៅតាមភូមិជារបរថ្មីមួយ ដែលអាចរកចំណូលបន្ថែមចូលក្នុងគ្រួសារ។ អ្នកស្រី ថេន សុផល មានវ័យ ៥០ឆ្នាំ អនុប្រធាន ក្រុមកែលម្អជីវភាព ភូមិទី១០ ឃុំព្រែកតានង់ ស្រុក កោះសូទិន ខេត្តកំពង់ចាម ដោយបានទទួលការគាំទ្រពីគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប។ បងស្រី ទទួលបាន មេមាន់ ចំនួន៥០ក្បាល ទូភ្ញាស់មួយ ស្បៀ១០គីឡូក្រាម ថ្នាំសម្លាប់មេរោគមួយដប និងចំណីបីបេ។

កំពុងលក់កូនមាន់ ឱ្យកសិកក្នុងភូមិយ៉ាងមមាញឹក អ្នកស្រីបាននិយាយដោយញញឹមថា "មានអ្នកមកទិញ កូនមាន់ច្រើនមួយថ្ងៃៗ ។ ខ្ញុំរីករាយនឹងការភ្ញាស់កូនមាន់ ដោយសារការចូលចិត្ត ជាមុខរបរនៅផ្ទះ និងអាចរកប្រាក់បានច្រើន"។ បងស្រី សុផល បង្ហើបឱ្យដឹងថាលទ្ធផលបានល្អ បើប្រៀបធៀបលើការចំណាយផ្សេងៗឃើញថា ការភ្ញាស់កូនគឺបានចំណេញគួរសមដែរ។ កូនមាន់មួយលក់បាន៥០០០រៀល៕

## ៥. ដំណាំម្រះនាំប្រាក់ច្រើនចូលផ្ទះ



មិនដូចពីមុននោះទេ គ្រួសាររបស់អ្នកស្រី យន់ គា សប្បាយរីករាយជាមុន។ ជាមួយនឹងដីមួយឡូនៅជាប់នឹងផ្ទះរបស់គាត់ ដែលមានប្រវែង១២ គុណ ៣៥ម៉ែត្រ អ្នកស្រី និងស្វាមី តែងតែមមាញឹកជានិច្ច។ ពួកគាត់ដាំបន្លែជាច្រើនប្រភេទ ទៅតាមរដូវកាលដូចជា ត្រសក់ផ្អែម សណ្តែកគួរ និងម្រះ។ ដោយមានទឹកមុខញញឹមពព្រាយ អ្នកស្រីបាននិយាយថា "ជីវភាពរបស់គ្រួសារខ្ញុំគឺ គ្រាន់បើជាងឆ្នាំមុនៗ ដោយសារតែឃើញប្រាក់ចំណូលពីការដាំបន្លែ" ។ គ្រួសាររបស់អ្នកស្រី យន់ គា គឺជាគ្រួសារមួយ ក្នុងចំណោមកសិករ ២៥គ្រួសារផ្សេងទៀតនៅក្នុងភូមិរោលផ្អែម ឃុំដូនតី ស្រុកញាក្រែក ខេត្តត្បូងឃ្មុំ ដែលត្រូវបានជ្រើសរើសដោយគម្រោងឱ្យធ្វើជាកសិករគំរូក្នុងក្រុមកែលម្អជីវភាព។ លោក ឯម វិសុទ្ធ ទីប្រឹក្សាកែលម្អជីវភាពបានឱ្យដឹងថា "ក្រុមកែលម្អជីវភាព ជ្រើសរើសឡើងតាមគោលការណ៍ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ដែលផ្អែកលើស្ថិតិគ្រួសារក្រីក្ររបស់ក្រសួងផែនការ កម្រិតក្រ១ និងតាមរយៈការវាយតម្លៃជាក់ស្តែង"។

ការវិភាគតម្លៃទីផ្សារ ត្រូវបានធ្វើឡើងជាទៀងទាត់ដោយមន្ត្រីរបស់គម្រោង និងសហការណ៍ជាមួយមន្ទីរកសិកម្ម ហើយព័ត៌មានស្តីពីតម្លៃត្រូវផ្តល់ជូនក្រុមកែលម្អជីវភាព តាមរយៈខិតប័ណ្ណដែលចែកដល់កសិករ ដើម្បីដឹងពីតម្លៃមូលដ្ឋាននៅតាមទីផ្សារ។ ខណៈកំពុងបេះម្រះ ជាមួយប្តីគាត់អ្នកស្រី យន់ គា បាននិយាយថា "ពេលមុន ខ្ញុំដាំឪឡឹក ដោយមិនបានដឹងច្បាស់ពីបច្ចេកទេស និងមិនបានដឹង ពីតម្លៃទីផ្សារទេ ប៉ុន្តែឥឡូវនេះ បានដឹងទាំងបច្ចេកទេស ទាំងតម្លៃលក់នៅលើទីផ្សារ។ ផលិតផល ដំណាំរបស់ខ្ញុំក៏បានល្អ អ្នកទិញ ក៏មិនអាចបន្ថោកតម្លៃតាមចិត្តបានទៀតទេ"។

អ្នកស្រី គា បានបន្ថែមថា ដំណាំម្រះចំណាយពេល ប្រហែល ២ខែ ទើបប្រមូលផល។ ក្នុងពេលប្រមូលផលពីរថ្ងៃបេះម្រះម្តង បានប្រហែល២០គីឡូ ។ អ្នកស្រី សំរាំងយកម្រះណាល្អៗ លេខមួយ ទៅលក់នៅផ្សារស្ទឹងជិតនេះ បានមួយគីឡូ ២៥០០០រៀល និងលេខ២ ទៅលក់ផ្សារកណ្តោលជ្រុំ បាន២០០០០រៀលក្នុងមួយគីឡូ។ ដោយទឹកមុខជឿជាក់ អ្នកស្រី យន់ គា និយាយថា ដោយសារដំណាំបន្លែនេះហើយដែលធ្វើឱ្យគ្រួសារខ្ញុំ មានជីវភាពធូរធាជាងមុន។ ខ្ញុំបានទិញម៉ាស៊ីនបូមទឹកមួយ និងកង់ឱ្យកូនជិះផងដែរ៕